ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.០០៣.....សហវ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## សារាចរណែនាំ
## ស្តីពី
## ការលើកលែងពន្ធលើប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ និងប្រាក់បំណាច់អតីតភាពការងារចាប់ពីឆ្នាំ២០១៩ តទៅមុខ និងសេវារកការងារឱ្យធ្វើ បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករឬកម្មសិក្សាការីទៅធ្វើការនៅបរទេស

អនុលោមតាមប្រកាសលេខ ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់ចំណេញ ប្រកាសលេខ ១១៧៣ សហវ.ពដ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់បៀវត្ស និងប្រកាសលេខ ៤៤៣ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ក្នុងគោលបំណងចូលរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់កម្មករនិយោជិតជាជនជាតិខ្មែរនៅតាមបណ្តាសហគ្រាសនានា និងដើម្បីកាត់បន្ថយបន្ទុកចំណាយរបស់ពលករទេសន្តរប្រវេសន៍ខ្មែរ ព្រមទាំងជួយពង្រីកទីផ្សារការងារនៅក្រៅប្រទេស និងលើកកម្ពស់ការបណ្តុះបណ្តាលជំនាញដល់ពលករ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចខាងក្រោម៖

១- លើកលែងពន្ធលើប្រាក់បៀវត្សចំពោះប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារ និងប្រាក់បំណាច់អតីតភាពការងាររបស់កម្មករនិយោជិតជាជនជាតិខ្មែរ នៃផ្នែកវាយនភណ្ឌកាត់ដេរនិងផលិតស្បែកជើង និងផ្នែកដទៃទៀត ដោយមិនគិតបញ្ចូលទៅក្នុងមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សឡើយ។

២- អនុញ្ញាតជាចំណាយអាចកាត់កងបានសម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូលក្នុងឆ្នាំជាប់ពន្ធចរន្ត ចំពោះការចំណាយរបស់សហគ្រាសលើការទូទាត់ប្រាក់បំណាច់អតីតភាពការងារចាប់ពីឆ្នាំ២០១៩ និងប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ តទៅមុខ។

៣- លើកលែងអាករលើតម្លៃបន្ថែមលើសេវារកការងារឱ្យធ្វើ បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករឬកម្មសិក្សាការីទៅធ្វើការនៅបរទេសរបស់ទីភ្នាក់ងារជ្រើសរើសឯកជន។

ទទួលបានសារាចរនេះ អគ្គនាយកដ្ឋានពន្ធដារ គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ថាប័នពាក់ព័ន្ធ រោងចក្រ សហគ្រាស ត្រូវសហការអនុវត្តឱ្យមានប្រសិទ្ធភាពនិងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្តេចវិបុលសេនាភក្តី អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សាលារាជធានី-ខេត្ត